# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## របបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បន្តស្លាប់ បាត់ខ្លួន និងពិការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ០៧ /នស/៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃ កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៧

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់របបឧបត្ថម្ភចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលបានពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ ។

**មាត្រា ២.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ ÷

- យោធិនពលី សំដៅដល់យោធិន ដែលបានបាត់បង់ជីវិត នៅពេលដែលបានទទួលបញ្ជាទៅប្រយុទ្ធ បម្រើការប្រយុទ្ធ ហ្វឹកហាត់ជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធន៍ដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិ

- យោធិនមរណៈ សំដៅដល់យោធិន ដែលបានទទួលបញ្ជាទៅបំពេញការងារក្នុងតំបន់ធម្មតា ហើយត្រូវទទួលគ្រោះថ្នាក់បាត់បង់ជីវិត ដោយសារការងារទាំងនោះ ឬដោយសារជំងឺ

- យោធិនបង្កស្លាប់ សំដៅដល់យោធិនដែលបានបាត់បង់ជីវិតដោយធ្វើអត្តឃាត ឬដោយសារបង្កគ្រោះថ្នាក់ ដល់បាត់បង់ជីវិតដោយផ្ទាល់ ឬប្រយោល មកពីល្មើសច្បាប់ វិន័យ និងបទបញ្ជា

- យោធិនបាត់ខ្លួន សំដៅដល់យោធិន ដែលបានទទួលបញ្ជាឱ្យទៅប្រយុទ្ធ បម្រើការប្រយុទ្ធ ហ្វឹកហាត់ជំនាញឯកទេស និងធ្វើការពិសោធន៍ប្រកបដោយគ្រោះថ្នាក់ ហើយត្រូវបាត់ខ្លួនដែលពុំអាចសន្និដ្ឋានបានថាស្លាប់ ឬ រស់ រត់ចោលជួរ រត់ចូលខ្មាំង ឬ ត្រូវខ្មាំងចាប់

- យោធិនពិការ សំដៅដល់យោធិនដែលបាត់បង់សរីរាង្គណាមួយ ឬច្រើននៅលើរាងកាយដោយបានចូលរួមប្រយុទ្ធ បម្រើការប្រយុទ្ធ ហ្វឹកហាត់ជំនាញគ្រោះថ្នាក់ ធ្វើការពិសោធន៍ដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិ ឬបំពេញការងារធម្មតា ។

## ជំពូកទី ២

## ប្រភេទយោធិនពិការ

**មាត្រា ៣.-**

យោធិនពិការ មាន២ ប្រភេទ គឺ ÷

- យោធិនពិការប្រភេទ "ក" ជាយោធិនមានជំងឺរបួសក្លាយជា យោធិនពិការដោយចូលរួមប្រយុទ្ធ បម្រើការប្រយុទ្ធ ហ្វឹកហាត់ជំនាញគ្រោះថ្នាក់ ធ្វើការពិសោធន៍ដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិ ត្រូវបានចែកចេញជា ៤ ថ្នាក់ ÷

-ថ្នាក់ទី ១ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ៨០ (ប៉ែតសិប) ភាគរយ

-ថ្នាក់ទី ២ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ៦០ (ហុកសិប) ភាគរយ

-ថ្នាក់ទី ៣ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ៤០ (សែសិប) ភាគរយ

-ថ្នាក់ទី ៤ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ២០ (ម្ភៃ) ភាគរយ

- យោធិនពិការប្រភេទ "ខ" ជាយោធិន ដែលមានជំងឺរបួស ក្លាយទៅជាយោធិនពិការ ដោយទទួលបញ្ជាទៅបំពេញការងារក្នុងតំបន់ធម្មតា ហើយត្រូវទទួលគ្រោះថ្នាក់ ត្រូវបានចែកចេញជា ៣ ថ្នាក់ ÷

-ថ្នាក់ទី ១ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ៨០ (ប៉ែតសិប) ភាគរយ

-ថ្នាក់ទី ២ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ៦០ (ហុកសិប) ភាគរយ

-ថ្នាក់ទី ៣ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ៤០ (សែសិប) ភាគរយ ។

**មាត្រា ៤.-**

យោធិនពិការប្រភេទ "ក" ដែលទទួលមរណៈភាព មានលិខិតបញ្ជាក់មរណៈភាព ត្រូវបានទទួលស្គាល់ជាយោធិនពលី ។

យោធិនពិការប្រភេទ "ក" ដែលរងរបួសបន្ថែមទៀត ដោយសារការចូលរួមប្រយុទ្ធ ឬបម្រើការប្រយុទ្ធ ឬបំពេញការងារធម្មតា ត្រូវបានពិនិត្យវាយតម្លៃថ្នាក់ពិការឡើងវិញ ។

**មាត្រា ៥.-**

យោធិនពិការប្រភេទ "ខ" ដែលទទួលមរណៈភាព មានលិខិតបញ្ជាក់មរណៈភាព ត្រូវបានទទួលស្គាល់ជាយោធិនមរណៈ ។

យោធិនពិការប្រភេទ "ខ" ដែលរងរបួសបន្ថែមទៀត ដោយសារការចូលរួមប្រយុទ្ធ ឬបម្រើការប្រយុទ្ធ ត្រូវទទួលស្គាល់ជាយោធិនពិការប្រភេទ "ក" វិញ ។

**មាត្រា ៦.-**

ការវាយតម្លៃប្រភេទថ្នាក់ពិការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាវាយតម្លៃមួយរបស់ក្រសួងការពារជាតិ ដោយផ្អែកតាមប្រកាសអន្តរក្រសួងរវាងក្រសួងការពារជាតិ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

## ជំពូកទី ៣
## របបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

**មាត្រា ៧.-**

យោធិនពលី ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ ÷

-ប្រាក់ឧបត្ថម្ភ ស្មើនឹងទឹកប្រាក់ចំនួន ៩ (ប្រាំបួន) ខែ នៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិនពលីជូនដល់គ្រួសារសព ឬកងឯកភាព ដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬ បញ្ចុះសព

-ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសព ស្មើនឹងទឹកប្រាក់ចំនួន ១៥ (ដប់ប្រាំ) ខែ នៃប្រាក់បៀវត្សរ៍សរុប ចុងក្រោយរបស់យោធិនពលី

-ប្រាក់ឧបត្ថម្ភជំនួយគ្រួសារជាប្រចាំខែ ជូនដល់ប្រពន្ធ ឬ ប្តី កូនបង្កើត ឪពុក ម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់យោធិនពលី តាមប្រកាសអន្តរក្រសួងរវាងក្រសួងការពារជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានការឯកភាពពីរាជរដ្ឋាភិបាល ។

**មាត្រា ៨.-**

យោធិនមរណៈ ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ ÷

-ប្រាក់ឧបត្ថម្ភ ស្មើនឹងទឹកប្រាក់ចំនួន ៧ (ប្រាំពីរ) ខែ នៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិនមរណៈ ជូនដល់គ្រួសារសព ឬកងឯកភាព ដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬ បញ្ចុះសព

-ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសពស្មើនឹងទឹកប្រាក់ចំនួន ១២ (ដប់ពីរ) ខែនៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិនមរណៈ

-ប្រាក់ឧបត្ថម្ភជំនួយគ្រួសារប្រចាំខែជូនដល់ប្រពន្ធ ឬប្តី កូនបង្កើត និងឪពុក ម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់យោធិនមរណៈ តាមប្រកាសអន្តរក្រសួងរវាងក្រសួងការពារជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានការឯកភាពពីរាជរដ្ឋាភិបាល ។

**មាត្រា ៩.-**

យោធិនបង្កស្លាប់ ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ ÷

-ប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៥ (ប្រាំ) ខែ នៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិនបង្កស្លាប់ ជូនដល់គ្រួសារសព ឬ កងឯកភាព ដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬ បញ្ចុះសព

-ប្រាក់ឧបត្ថម្ភមួយលើកផ្តាច់ជូនដល់គ្រួសារសពស្មើនឹងទឹកប្រាក់ចំនួន ១២ (ដប់ពីរ) ខែ នៃប្រាក់បៀវត្សរ៍ សរុបចុងក្រោយរបស់យោធិនបង្កស្លាប់ ។

**មាត្រា ១០.-**

យោធិនបាត់ខ្លួន ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ ៖

-ប្រាក់ឧបត្ថម្ភជូនគ្រួសារស្មើនឹងទឹកប្រាក់បៀវត្សរ៍សរុបចុងក្រោយ របស់យោធិនបាត់ខ្លួន ដោយគិតទាំងរបបអង្គរប្រចាំខែ ចាប់ពីខែ ឆ្នាំ បាត់ខ្លួនរហូតដល់គម្រប់ ១២ (ដប់ពីរ) ខែ

-ក្រោយ១២(ដប់ពីរ)ខែ គិតពីខែ ឆ្នាំ បាត់ខ្លួនមក គ្រួសារត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចជា យោធិនពលី លើកលែងតែប្រាក់ឧបត្ថម្ភសម្រាប់បូជាសព ឬ បញ្ចុះសពចេញ ។

ក្នុងអំឡុងពេលកំពុងទទួលរបបឧបត្ថម្ភណាមួយក្នុងចំណុចទាំងពីរខាងលើ ប្រសិនបើយោធិន បាត់ខ្លួនបានវិលត្រឡប់មកកងឯកភាពដើម ឬ វិលទៅមូលដ្ឋានវិញ ការផ្តល់របបឧបត្ថម្ភត្រូវតែបញ្ឈប់ចាប់ពី ខែ ឆ្នាំ ដែលយោធិនបាត់ខ្លួន នោះមានមុខ ។

**មាត្រា ១១.-**

ជនដែលមានគ្រប់លក្ខណៈសម្បត្តិ ដែលអាចទទួលរបបឧបត្ថម្ភពីយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន មានដូចតទៅ ៖

-ឪពុក និងម្តាយបង្កើត ឬអ្នកអាណាព្យាបាលតាំងពីវ័យកុមារ របស់យោធិន បើសិនជាយោធិននោះ នៅលីវ

- ប្រពន្ធ ឬ ប្តី របស់យោធិនមានលិខិតអាពាហ៍ពិពាហ៍ ហើយពុំទាន់រៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត

- កូនបង្កើត របស់យោធិនមានសំបុត្រកំណើតអាយុ១៨ (ដប់ប្រាំបី) ឆ្នាំចុះ និងមានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើង ត្រូវមានលិខិតបញ្ជាក់កំពុងបន្តការសិក្សា ហើយពុំទាន់ទទួលនូវអាហារូបករណ៍ ឬ មាន លិខិតបញ្ជាក់ពិការភាព

-ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលដែលមានកូនពលី ឬមរណៈ១(មួយ)នាក់ ឬ ២(ពីរ)នាក់ ឡើងទៅ ត្រូវបានទទួលរបបឧបត្ថម្ភគុណតាមចំនួនកូនដែលបានពលី ឬមរណៈនោះ ។

**មាត្រា ១២.-**

របបឧបត្ថម្ភ ចំពោះយោធិនពិការប្រភេទ " ក " មានដូចតទៅ ៖

១-ក្រោយពេលព្យាបាលជំងឺរបួសជាសះស្បើយ និងមានលំនឹង ត្រូវបានទទួលរបបឧបត្ថម្ភបំប៉ន សុខភាពនៅមជ្ឈមណ្ឌលបំប៉នសុខភាព តាមរយៈពេលកំណត់ និងតាមថ្នាក់ពិការគឺ ៖

-ថ្នាក់ទី ១ បានអនុញ្ញាតឱ្យសម្រាកបំប៉នសុខភាពចំនួន ៩០ (កៅសិប) ថ្ងៃ

-ថ្នាក់ទី ២ បានអនុញ្ញាតឱ្យសម្រាកបំប៉នសុខភាពចំនួន ៦០ (ហុកសិប) ថ្ងៃ

-ថ្នាក់ទី ៣ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួន ៤៥ (សែសិបប្រាំ) ថ្ងៃ

-ថ្នាក់ទី ៤ បានអនុញ្ញាតឱ្យសម្រាកបំប៉នសុខភាពចំនួន ៣០ (សាមសិប) ថ្ងៃ ។

២-ប្រសិនបើយោធិនពិការ នៅបន្តការងារក្នុងកងយោធពលខេមរភូមិន្ទ ត្រូវបានទទួលរបបឧបត្ថម្ភជំនួយមុខរបួសបន្ថែមជាប្រចាំខែ ដោយគិតជាសមាមាត្រភាគរយនៃប្រៀវត្សរ៍សរុបប្រចាំខែផ្ទាល់ខ្លួន និងតាមកម្រិតថ្នាក់ពិការបន្ថែមលើប្រាក់បៀវត្សរ៍ប្រចាំខែផ្ទាល់ខ្លួន ÷

-ថ្នាក់ទី ១ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង៤៥ (សែសិបប្រាំ) ភាគរយនៃប្រាក់បៀវត្សរ៍ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ

-ថ្នាក់ទី ២ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង ៤០ (សែសិប) ភាគរយនៃប្រាក់បៀវត្សរ៍ ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ

-ថ្នាក់ទី ៣ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង ៣៥ (សាមសិបប្រាំ) ភាគរយនៃប្រាក់បៀវត្សរ៍ ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ

-ថ្នាក់ទី ៤ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង ៣០ (សាមសិប) ភាគរយនៃប្រាក់បៀវត្សរ៍ ផ្ទាល់ខ្លួនចុងក្រោយ របស់យោធិនពិការនោះ ។

៣-យោធិនពិការ ដែលក្រសួងការពារជាតិសម្រេចអោយចេញពីជួរកងយោធពលខេមរភូមិន្ទ ត្រូវបាន ទទួលរបបឧបត្ថម្ភប្រាក់អតីតភាពបម្រើការងារមិនលើសពី ២៤ (ម្ភៃបួន) ខែ ដោយគិតរយៈពេលបម្រើកងយោធពលខេមរភូមិន្ទក្នុង១ (មួយ) ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ២ (ពីរ) ខែ។ ចំពោះយោធិនពិការដែលបម្រើកងទ័ពមិនទាន់គ្រប់រយៈពេល ១ (មួយ) ឆ្នាំ ហើយត្រូវពិការ ក៏ត្រូវបានទទួលប្រាក់អតីតភាពចំនួន ២ (ពីរ) ខែ ដែរ ។

៤-យោធិនពិការ ត្រូវបានទទួលរបបឧបត្ថម្ភមួយលើកដំបូងស្មើនឹងទឹកប្រាក់ចំនួន ÷

-ថ្នាក់ទី ១ ទទួលទឹកប្រាក់សរុបចំនួន ១២ (ដប់ពីរ) ខែ នៃប្រាក់បៀវត្សរ៍សរុប ចុងក្រោយរបស់យោធិន ពិការនោះ

-ថ្នាក់ទី ២ ទទួលទឹកប្រាក់សរុបចំនួន ១០ (ដប់) ខែ នៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិន ពិការនោះ

-ថ្នាក់ទី ៣ ទទួលទឹកប្រាក់សរុបចំនួន ៨ (ប្រាំបី) ខែ នៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិន ពិការនោះ

-ថ្នាក់ទី ៤ ទទួលទឹកប្រាក់សរុបចំនួន ៦ (ប្រាំមួយ) ខែ នៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិន ពិការនោះ ។

៥-បានបន្តទទួលបើកប្រាក់បៀវត្សរ៍សរុបប្រចាំខែ ហើយបៀវត្សរ៍សរុបនោះ ត្រូវគិតតាមឋានន្តរសក្តិចុងក្រោយមុនពេលសម្រេចឱ្យចេញពីជួរកងយោធពលខេមរភូមិន្ទ - និងចំនួនកូននៅក្នុងបន្ទុក

ជាក់ស្តែង របស់យោធិនពិការ ។

៦-យោធិនពិការ ដែលរស់នៅក្នុងមណ្ឌល យោធិនដែលចេញពីជួរកងយោធពលខេមរភូមិន្ទ ត្រូវបាន ទទួលបន្ថែមនូវប្រាក់ឧបត្ថម្ភជំនួយមុខរបួសជារៀងរាល់ខែ ដោយគិតជាសមាមាត្រលើប្រាក់បៀវត្សរ៍សរុប ប្រចាំខែ ដូចខាងក្រោម ៖

-ថ្នាក់ទី ១ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹង ១០០ ( មួយរយ) ភាគរយ

-ថ្នាក់ទី ២ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹង ៨០ (ប៉ែតសិប) ភាគរយ

-ថ្នាក់ទី ៣ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹង ៦០ (ហុកសិប) ភាគរយ

-ថ្នាក់ទី ៤ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹង ៤០ (សែសិប) ភាគរយ ។

៧-យោធិនពិការកម្រិតថ្នាក់១ បានទទួលរបបឧបត្ថម្ភអ្នកបំរើផ្ទាល់ខ្លួនមួយនាក់ ហើយអ្នកបម្រើនោះ ត្រូវបានទទួលជាប្រចាំខែ រហូតដល់យោធិននោះស្លាប់ ស្មើនឹងបៀវត្សរ៍អប្បបរមាផ្ទាល់ខ្លួនរបស់យោធិនមាន ឋានន្តរសក្តិ ជាពលទោ ។

**មាត្រា ១៣.-**

របបឧបត្ថម្ភ ចំពោះយោធិនពិការប្រភេទ " ខ " មានដូចតទៅ ៖

១-យោធិនពិការដែលក្រសួងការពារជាតិសម្រេចឱ្យចេញពីជួរកងយោធពលខេមរភូមិន្ទ នឹងបាន ទទួលប្រាក់ឧបត្ថម្ភអតីតភាពបម្រើការងារមិនលើសពី ៨(ប្រាំបី)ខែ ដោយគិតរយៈពេលបម្រើកងយោធពល-ខេមរភូមិន្ទ ក្នុង ១(មួយ)ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ២(ពីរ)ខែ ។ ចំពោះយោធិនពិការ ដែលបម្រើកងទ័ពមិនទាន់គ្រប់រយៈពេល ១(មួយ)ឆ្នាំ ហើយត្រូវពិការក៏ត្រូវបានទទួលប្រាក់អតីតភាពចំនួន២ (ពីរ)ខែ ដែរ ។

២-យោធិនពិការ ត្រូវបានទទួលរបបឧបត្ថម្ភជាប្រចាំតាមថ្នាក់ពិការ តាមសមាមាត្រភាគរយនៃ ប្រាក់បៀវត្សរ៍ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការ ៖

-ថ្នាក់ទី ១ បានទទួលទឹកប្រាក់សរុបស្មើនឹង ៩០ (កៅសិប) ភាគរយនៃបៀវត្សរ៍ផ្ទាល់ ខ្លួនចុងក្រោយរបស់យោធិនពិការនោះ

-ថ្នាក់ទី ២ បានទទួលទឹកប្រាក់សរុបស្មើនឹង ៨០ (ប៉ែតសិប) ភាគរយនៃបៀវត្សរ៍ផ្ទាល់ ខ្លួនចុងក្រោយរបស់យោធិនពិការនោះ

-ថ្នាក់ទី ៣ បានទទួលទឹកប្រាក់សរុបស្មើនឹង ៧០ (ចិតសិប) ភាគរយនៃបៀវត្សរ៍ផ្ទាល់ ខ្លួនចុងក្រោយរបស់យោធិនពិការនោះ

-ត្រូវបានទទួលឧបត្ថម្ភចិញ្ចឹមប្រពន្ធ ឬប្តី កូន ដូចយោធិនពិការប្រភេទ " ក " ។

**មាត្រា ១៤.-**

យោធិនពិការទាំង ២ ប្រភេទ គ្រប់ថ្នាក់ ត្រូវបានទទួលរបបឧបត្ថម្ភបន្ថែមដូចតទៅ ÷

១-រាល់ថ្ងៃបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងថ្ងៃបុណ្យខួបរំលឹកគុណយោធិនពលី ពិការ (កំណត់ថ្ងៃបុណ្យភ្ជុំបិណ្ឌ) ត្រូវបានទទួលរបបឧបត្ថម្ភស្មើនឹងទឹកប្រាក់ឧបត្ថម្ភថ្ងៃបុណ្យរបស់មន្ត្រីរាជការកំពុងធ្វើការងារ ។

២-ពេលមានជំងឺ របួស ឬ ពេលរបួសសើរើ ត្រូវបានទទួលសង្គ្រោះព្យាបាលលុះជាសះស្បើយ នៅតាមមន្ទីរពេទ្យរដ្ឋ ដោយឥតគិតថ្លៃ ។

៣-យោធិនពិការទាំងពីរភេទ ត្រូវបានរដ្ឋជួយស្តារលទ្ធភាពពលកម្ម កាយសម្បទា និងផ្តល់ឧបករណ៍ទ្រទ្រង់រាងកាយ ដោយឥតបង់ប្រាក់ ជួយបណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កឱ្យមានមុខរបរសមស្របតាមសមត្ថភាព និងលទ្ធភាពជាក់ស្តែង ។

៤-យោធិននារីពិការ ត្រូវបានទទួលឧបត្ថម្ភបន្ថែមនូវការធានារ៉ាប់រងសង្គមដូចស្ត្រីដែលកំពុងបម្រើការងាររាជការដែរ ។

៥-យោធិនពិការ ដែលបម្រើការងារនៅពេលគ្រប់លក្ខណៈសម្បត្តិចូលនិវត្តន៍ ត្រូវផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីដោះស្រាយប្រាក់ឧបត្ថម្ភជំនួយមុខរបួស និងប្រាក់សោធននិវត្តន៍វិញ ។

## ជំពូកទី ៤

## ការទទួលខុសត្រូវលើរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

**មាត្រា ១៥.-**

ក្រសួងការពារជាតិ ជាអ្នកទទួលបន្ទុកដោះស្រាយនូវរាល់ការចំណាយដូចខាងក្រោម ÷

- សម្រាប់ការបូជា ឬបញ្ចុះសព
- សម្រាប់ឧបត្ថម្ភជូនគ្រួសារយោធិនពលី មរណៈ បង្កស្លាប់ មួយលើកដំបូង
- សម្រាប់ឧបត្ថម្ភបំប៉នសុខភាពយោធិនពិការ
- សម្រាប់ឧបត្ថម្ភប្រាក់អតីតភាពការងាររបស់យោធិនពិការ មុនពេលសម្រេចឱ្យចេញពីជួរកងយោធពលខេមរភូមិន្ទ
- សម្រាប់ឧបត្ថម្ភជំនួយមុខរបួសរបស់យោធិនពិការ នៅបន្តការងារក្នុងកងយោធពល-ខេមរភូមិន្ទ

- ដោះស្រាយប្រាក់បៀវត្សរ៍សរុប ៣ (បី) ខែ មុនពេលផ្ទេរយោធិនពិការទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងរយៈពេលរង់ចាំ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បំពេញសំណុំលិខិតដោះស្រាយប្រាក់ឧបត្ថម្ភបន្ត ។

**មាត្រា ១៦.-**

ក្រៅពីរបបឧបត្ថម្ភ ដែលក្រសួងការពារជាតិទទួលបន្ទុកដោះស្រាយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកទទួលបន្ទុកដោះស្រាយបន្ត ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

អនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ និងអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយក រដ្ឋមន្ត្រី
- ដូចមាត្រា ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ